# មិននិយាយមិនបាន

ជាឱកាសល្អណាស់ដែលខ្ញុំបានចូលរួមចំណែកក្នុងការសរសេររឿងរ៉ាវសោកនាដកម្មនិងឧក្រិដ្ឋកម្មមហាព្រៃផ្សៃដែលប្រវត្តិសាស្ត្រមនុស្សលោកមិនធ្លាប់បានជួបប្រទះ ហើយដោយខ្ញុំធ្លាប់បានឆ្លងកាត់ជាក់ស្តែងក្នុងរបបឃោរឃៅដ៏ឆ្កួតលេលារបស់កម្ពុជាប្រជាធិបតេយ្យនោះ ។ ខ្ញុំបានសម្រេចចិត្តសរសេរអត្ថបទនេះជាឯកសារសម្រាប់កូនចៅជំនាន់ក្រោយតទៅទៀត ។

សូមកុំគិតថាពេលវេលាដែលកន្លងទៅទទេឲ្យសោះ ។ ប្រជាជនខ្មែរជាអ្នករងគ្រោះនិងមានជំងឺផ្លូវចិត្តបែកបាក់ខ្ទេចខ្ទាំរាំរៃជាងគេក្នុងពិភពលោកនេះ ។ ក្នុងនាមខ្ញុំជាខ្មែររងគ្រោះម្នាក់ ខ្ញុំគិតថា បើខ្ញុំមិនព្រមចូលរួមក្នុងការសរសេរការពិតដែលខ្ញុំបានដឹងឮនិងជួបប្រទះព្រមទាំងទទួលរងនូវការឈឺចាប់ដ៏ខ្លាំងក្លាបរិយាយពុំបាន គឺមានន័យថាខ្ញុំជាមនុស្សសោះអង្គើយនឹងការរំលោភលើសិទ្ធិមនុស្សជាតិ ហើយផ្តេកផ្តួលលើកម្មវាសនាប្រៃជន្ម ។

ខ្ញុំធ្លាប់ដឹងតាមសភាពជារាស្ត្រសាមញ្ញថាទុក្ខលំបាកវេទនារបស់ប្រជាជនខ្មែរគឺមិនមែនមកពីសីលធម៌អគតិរបស់អ្នកដឹកនាំប្រទេសនោះទេ ។ ប្រសិនបើអ្នកដឹកនាំស្រុកទេសមានគតិបណ្ឌិត ទសពិធរាជធម៌ ព្រហ្មវិហារធម៌ និងអនុវត្តឲ្យបានល្អត្រឹមត្រូវតាមគោលការណ៍នេះ ប្រទេសកម្ពុជាដែលធ្លាប់ជាប្រទេសមានកិត្យានុភាពរុងរឿងពីសម័យមហានគរមិនមែនធ្លាក់ខ្លួនយ៉ាងគំហុកដូចឥឡូវនេះទេ ។ ប្រជារាស្ត្រកម្ពុជានិងសកលលោកដឹងច្បាស់ណាស់ថា គឺគ្មានអ្នកណាធ្វើឲ្យយើងអន់ក្រៅពីខ្លួនយើងនោះទេ ។

អតីតកាលកន្លងទៅ ប៉ុន្តែវាអាចហុចផលជាមេរៀនល្អនិងអាក្រក់ឲ្យយើងចងចាំនិងទប់ស្កាត់បង្ការទំនាស់មិនឲ្យកើតមានជាថ្មីទៀត ។ សូមអ្នកដឹកនាំដែលមានចំណេះដឹងជ្រៅជ្រះនិងអ្នកដឹកនាំឆោតល្ងង់ដែលមិនសូវដឹងខុសដឹងត្រូវល្មមភ្ញាក់រឭកឡើង បើចង់ឲ្យដែនដីនិងឈ្មោះខ្មែរមានលើសកលលោកនឹងគេ ។ សូមត្រួតពិនិត្យឡើងវិញ ហើយកែខ្លួនដោយឆ្លុះបញ្ចាំងទង្វើអាក្រក់ ដែលប្រឆាំងនឹងសីលធម៌ពុទ្ធសាសនានិយមរបស់ខ្លួនប្រឆាំងនឹងច្បាប់និងសិទ្ធិរបស់មនុស្សជាតិនៃពិភពលោកទាំងមូលផង ដែលគេដឹងកាន់តែច្រើនឡើងៗនិងមានបំណងចង់រកយុត្តិធម៌ឲ្យប្រជាពលរដ្ឋខ្មែរដែលរងគ្រោះនៅក្រោមរបបដ៏ព្រៃផ្សៃរបស់មេដឹកនាំទាំងនោះ ។

មិនបាច់ទម្លាក់កំហុសលើអ្នកណាយករួចខ្លួនទេ ។ ប៉ុន្តែដាច់ខាតត្រូវតែមានតុលាការអន្តរជាតិដើម្បីកាត់ទោសឧក្រិដ្ឋជនភេរវជនប្រឆាំងនឹងសិទ្ធិមនុស្ស ។ ខ្ញុំមិនមានជំនឿថាតុលាការនៅក្នុងស្រុកតែឯកឯងនឹងមិនអាចរកយុត្តិធម៌ឲ្យជនរងគ្រោះខ្មែរដែលសល់ពីស្លាប់ក្រោមរបបប្រល័យពូជសាសន៍បានឡើយពីព្រោះថា តុលាការនេះជាតុលាការដែលមានសមាសភាពដៃដល់កាន់ជើងជនដៃដល់ទាំងអស់នោះដែរ ។ ប្រជារាស្ត្រខ្មែរទាំងអស់មិនទទួលយកភាពបន្លំក្លែងក្លាយរបស់ជនអសោចកាត់ទោសជនអសោចគ្នាឯងក្រោមរូបភាពផ្សះផ្សាជាតិនិងលើកលែងទោសពីសំណាក់ជនណាជាដាច់ខាត ។ សូមគាំទ្រទាំងស្រុងការបង្កើតឲ្យមានតុលាការអន្តរជាតិត្រឹមត្រូវមួយដ៏យុត្តិធម៌ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមនិងជនដៃដល់កំបាំងមុខមួយចំនួនដែលបាននិងកំពុងតែទាញស្រុកទេសព្រមទាំងប្រជារាស្ត្រឲ្យធ្លាក់រណ្តៅជ្រៅរកទាំងរស់ ។

ខ្ញុំសូមអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជានិងដល់លោកនាយកទស្សនាវដ្តីស្វែងរកការពិតព្រមទាំងសហការីទាំងអស់ដែលបាននិងបន្តការខិតខំស្រាវជ្រាវ ចងក្រងនិងប្រមូលផ្តុំនូវភ័ស្តុតាងទាំងឡាយសម្រាប់តម្កល់ជួយដល់តុលាការអន្តរជាតិរបស់អង្គការសហប្រជាជាតិ ដើម្បីជំនុំជម្រះជនដែលអនុវត្តផែនការបរទេសដោយចេតនាសម្លាប់រង្គាលប្រជាជាតិឯងដើម្បីពង្រីកមនោគមវិជ្ជាកុម្មុយនិស្តលើប្រទេសកម្ពុជាក៏ដូចអាស៊ី-អាគ្នេយ៍ ។ ខ្ញុំសូមបួងសួងដល់ព្រះជាម្ចាស់ សូមព្រះអង្គផ្តល់ប្រាជ្ញាដល់សេចក្តីសម្រេចរបស់អ្នកស្នេហាយុត្តិធម៌និងសិទ្ធិមនុស្សពិតប្រាកដរបស់អង្គការសហប្រជាជាតិ ។ **ឡាច ឆខាង**